នាំចេញប្រចាំឆ្នាំ នៃជ័រទឹកប្រមូលបានក្នុងមួយឆ្នាំៗ ប្រមាណ ១១.០០០តោន ទៅ ១៨.០០០តោន មានប្រហែល ៤,៧លានដុល្លារ ទៅ ៧,៦លានដុល្លារ ។

ប្រជាជនជនបទភាគច្រើន ពឹងផ្អែកលើធនធានព្រៃឈើ ដើម្បីដោះស្រាយតម្រូវការប្រើប្រាស់ថាមពល ។ យោងតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣ (RGC ២០១០) នៅឆ្នាំ២០០៨ គ្រួសារនៅកម្ពុជាសរុប ៧៣% ពឹងផ្អែកលើអុស ហើយអត្រានេះធ្លាក់ចុះមកត្រឹម ៦៧% នៅឆ្នាំ២០០៩ និង ៦១% នៅឆ្នាំ២០១០ ។ ក្រៅពីការប្រើប្រាស់ឈើជាប្រភពថាមពល ប្រជាជនជនបទត្រូវការឈើ សម្រាប់ប្រើជាសម្ភារៈសំណង់ និងប្រមូលផលនិងអនុផលព្រៃឈើជាច្រើនទៀត ដូចជា ឫស្សី ទំពាំង និងបន្លែព្រៃ ដើម្បីលើកកម្ពស់ជីវភាព និងបំពេញតម្រូវការប្រើប្រាស់ប្រចាំថ្ងៃរបស់ខ្លួន ។ ព្រៃឈើដើរតួនាទីដ៏សំខាន់ ក្នុងការធានាសុវត្ថិភាពស្បៀងអាហារសម្រាប់ប្រជាជនមូលដ្ឋាន ជាពិសេសសម្រាប់សហគមន៍ស្ថិតនៅក្បែរព្រៃឈើ ។ ក្នុងឆ្នាំ២០០៨ អនុវិស័យព្រៃឈើរួមចំណែក ៦,៩% នៃ ផសសសរុបរបស់វិស័យកសិកម្ម (Chao 2009) ។

ពិតហើយ ព្រៃឈើផ្តល់ផលប្រយោជន៍ជាច្រើនដល់ប្រជាជនមូលដ្ឋាន ប៉ុន្តែដោយសារយើងមិនដឹងពីតម្លៃគិតជាប្រាក់នៃធនធាន ដែលប្រជាជនមូលដ្ឋានទាញយកពីព្រៃឈើ ដូច្នេះ យើងក៏មិនដឹងថា តើព្រៃឈើរួមចំណែកប៉ុណ្ណាដល់ការកាត់បន្ថយភាពក្រីក្រដែរ ។ មានការសិក្សាជាច្រើនបានធ្វើឡើងនៅកម្ពុជា ប៉ុន្តែ របាយការណ៍ទាក់ទងនឹងតម្លៃពិតប្រាកដនៃធនធានព្រៃឈើសម្រាប់ជីវភាពមូលដ្ឋាន មានតិចតួចណាស់ ។ លទ្ធផលការសិក្សាភាគច្រើន ទទួលបានពីសម្ភាសន៍សុំព័ត៌មានលើអំឡុងពេលមួយយ៉ាងខ្លី ឬការពិភាក្សាតាមក្រុមស្នូលផ្អែកលើព័ត៌មានអ្នកចូលរួមបានចងចាំក្នុងរយៈពេលមួយឆ្នាំពេញ ដែលអាចមានការភ្លេចភ្លាំង ការរាយការណ៍មិនអស់ ឬការរាយការណ៍ពីរដងអំពីផលព្រៃឈើប្រមូលបាន ។ អ្នកស្រាវជ្រាវដទៃទៀត បានផ្តោតលើតម្លៃនៃធនធានធម្មជាតិជារួម ចំពោះសហគមន៍មូលដ្ឋាន ប៉ុន្តែមានអ្នកស្រាវជ្រាវតិចនាក់ណាស់ ដែលបានស្វែងរកតម្លៃនៃធនធានព្រៃឈើជាក់លាក់ ចំពោះចំណូលនៅកម្រិតគ្រួសារ ។ ដូច្នេះ ត្រូវមានការអនុម័តយកវិធីសាស្ត្រមួយ សម្រាប់ប៉ាន់ស្មានតម្លៃផលិតផលព្រៃឈើ ដែលអ្នកប្រើប្រាស់ព្រៃឈើប្រមូលបាន ដើម្បីកែលំអគុណភាពទិន្នន័យ និងទទួលបានលទ្ធផលកាន់តែមានប្រយោជន៍ ។

ឯកសារនេះ ជាលទ្ធផលនៃការសិក្សាមួយស្តីពី "ព្រៃតំបន់ត្រូពិចសម្រាប់ការកាត់បន្ថយភាពក្រីក្រ៖ ការវិភាគតាំងពីទិន្នន័យគ្រួសារដល់ទិន្នន័យសាកល" ដែលជាគម្រោងរួមគ្នារវាង ១) មជ្ឈមណ្ឌលសម្រាប់ព្រៃឈើ ទេសភាព និងការរៀបចំផែនការ (S & L) នៃមហាវិទ្យាល័យវិទ្យាសាស្ត្រជីវិត ប្រចាំសាកលវិទ្យាល័យ Copenhagen (KU) ២) កម្មវិធីព្រៃឈើ និងជីវភាព នៃមជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវពីព្រៃឈើអន្តរជាតិ (CIFOR) ៣) វិទ្យាស្ថានស្រាវជ្រាវព្រៃឈើនៃប្រទេសហ្កាណា (FORIG) ៤) ដេប៉ាតេម៉ង់សង្គមវិទ្យានៃសាកលវិទ្យាល័យ Ouagadougou (DSUO) នៃប្រទេស Burkina Faso និង ៥)

ក្រាហ្វិក១៖ តំបន់សិក្សា



វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ។ គម្រោងនេះ ទទួលមូលនិធិពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក (DANIDA) ។

ការសិក្សានេះផ្តោតលើ ១) វិធីសាស្ត្រប៉ាន់ស្មានថ្លៃផលិតផលព្រៃឈើ ដែលរួមមាន ការប្រើប្រាស់ និងការលក់ដូរ និង ២) ការរួមចំណែកនៃចំណូលពីព្រៃឈើក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនមូលដ្ឋាន ។

## វិធីសាស្ត្រ

### *តំបន់សិក្សា*

ការសិក្សាបានអនុវត្តក្នុង ១៥ភូមិ នៅឃុំតាកែន ខេត្តកំពត ឃុំសង្កែសាទប ខេត្តកំពង់ស្ពឺ និងឃុំទំរីង ខេត្តកំពង់ធំ (ក្រាហ្វិក ១) ។ គម្របដីសំខាន់ៗក្នុងឃុំនីមួយៗ មានពិពណ៌នាដោយសង្ខេបនៅខាងក្រោម ។

- *ឃុំតាកែន៖* គម្របដីចំបងៗ រួមមាន ព្រៃស្រោង ព្រៃរបោះ និងព្រៃឈើដុះឡើងវិញ បន្ទាប់ពីរងការបំផ្លិចបំផ្លាញ ។ តំបន់នេះ បើកទូលាយឲ្យអ្នកភូមិទាំងអស់ មានលទ្ធភាពប្រើប្រាស់ធនធានព្រៃឈើ និងមានមួយភាគបានកំណត់ទុកជាតំបន់ការពារធម្មជាតិ ។

- *ឃុំសង្កែសាទប៖* គម្របដីអាចបែងចែកជា ព្រៃរបោះ ព្រៃដុះឡើងវិញ និងព្រៃគុម្ពោត ។ ឃុំបានបង្កើតជាសហគមន៍ព្រៃឈើ ហើយតំបន់នេះជាផ្នែកមួយនៃតំបន់ការពារធម្មជាតិ ។

- *ឃុំទំរីង៖* គម្របដីភាគច្រើនជា ព្រៃស្រោង ព្រៃរបោះ និងព្រៃឈើដុះឡើងវិញ ។ ក្នុងពីរបីឆ្នាំមុនពេលក្រុមស្រាវជ្រាវចុះធ្វើអង្កេត ការប្រើប្រាស់ដីនៅតំបន់នេះ បានប្រែប្រួលយ៉ាងខ្លាំង ដោយសារការបង្កើតចំការកៅស៊ូ ។

### *អង្កេតគ្រួសារ*

ដើម្បីទទួលបានគំរូតាងល្អ និងលទ្ធផលមានលក្ខណៈតំណាង និងគួរឲ្យជឿជាក់ ក្រុមស្រាវជ្រាវបានធ្វើសម្ភាស ៦០០គ្រួសារ ឬ ប្រហែល ២០០គ្រួសារ នៅ ៥ភូមិ ក្នុងឃុំនីមួយៗ ។ សម្ភាសន៍នេះធ្វើឡើងជា ៤ដង នៅខែ មករា មីនា-មេសា មិថុនា-កក្កដា និងតុលា-វិច្ឆិកា ក្នុងឆ្នាំ២០០៨ ដើម្បីបង្កើតមូលដ្ឋានសុីគ្នាមួយសម្រាប់ការប្រមូលទិន្នន័យ និងកាត់បន្ថយការលំបាករបស់អ្នកឆ្លើយសម្ភាសន៍ ក្នុងការនឹករកព័ត៌មានទាក់ទងនឹងផលព្រៃឈើដែលខ្លួនបានប្រមូល ។

សម្រាប់ការធ្វើសម្ភាសន៍ ប្រហែល ៤០គ្រួសារ ឬ ១០-៣០% នៃគ្រួសារសរុបក្នុងភូមិនីមួយៗ ត្រូវបានជ្រើសរើសដោយចៃដន្យ និងស្របតាមគោលការណ៍ណែនាំខាងបច្ចេកទេសរបស់បណ្តាញបរិស្ថាន និងភាពក្រីក្រ (PEN) (២០០៧) ដែលចែងថា គ្រួសារគំរូតាងត្រូវជ្រើសរើសដោយចៃដន្យចេញពីចំនួនប្រជាជនសរុប ។ បន្ទាប់មក មានការបិទសញ្ញាសំគាល់ពណ៌លឿងនៅលើជញ្ជាំងមុខផ្ទះនីមួយៗ ដើម្បីជួយឲ្យអ្នកចុះធ្វើអង្កេតងាយស្រួលស្វែងរកគ្រួសារគំរូតាងទាំងនោះ នៅវគ្គចុះអង្កេតលើកក្រោយៗទៀត ។

គំរូបញ្ជីសំណួរលើកទី៤ របស់ PEN ដែលបានចងក្រងជាភាសាអង់គ្លេស បានយកមកប្រើសម្រាប់ធ្វើអង្កេតគ្រួសារនៅត្រីមាសទី១ ទី២ ទី៣ និងទី៤ ។ បញ្ជីសំណួរបានបកប្រែជាភាសាខ្មែរ ដើម្បីធានាការប្រមូលទិន្នន័យប្រកបដោយគុណភាពខ្ពស់ ។

ដោយសារអង្កេតនេះ ផ្អែកលើការចងចាំរបស់អ្នកឆ្លើយសម្ភាសន៍ អំពីចំណូលដែលពួកគាត់រកបានពីព្រៃឈើ និងផលព្រៃឈើផ្សេងៗ សម្រាប់ការប្រើប្រាស់ក្នុងត្រីមាសនីមួយៗ ដូច្នេះ ទិន្នន័យទទួលបាន អាចមានភាពមិនច្បាស់ ដោយសារអ្នកឆ្លើយសម្ភាសន៍ផ្តល់ព័ត៌មាន មិនមែនកើតឡើងក្នុងត្រីមាសកំពុងធ្វើអង្កេត ហើយនិងការរាយការណ៍រឿងមួយដល់ទៅពីរដង ។ ដើម្បីធានាថា ទិន្នន័យដែលទទួលបានជាព័ត៌មានក្នុងត្រីមាសកំពុងធ្វើអង្កេត ក្រុមស្រាវជ្រាវបានធ្វើការផ្ទៀងផ្ទាត់ និងបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យដែលទទួលបាននៅវគ្គថ្មី ដោយធៀបនឹងទិន្នន័យប្រមូលបាននៅវគ្គមុន ។

### *ការប៉ាន់ស្មានថ្លៃផលិតផល*

ការសិក្សានេះ សំដៅកំណត់តម្លៃផលិតផលទាំងអស់ ដែលប្រមូលបានពីព្រៃឈើ គិតជាទឹកប្រាក់ ។ ដូច្នេះ ការប្រមូលព័ត៌មានទាក់ទងនឹងថ្លៃផលិតផលព្រៃឈើ ពីក្រុមគ្រួសារគំរូតាងមានសារៈសំខាន់ណាស់ ។ ក្រុមស្រាវជ្រាវបានរៀបចំវិធីសាស្ត្រចំនួន ៣ ដើម្បីគណនាថ្លៃផលិតផលៈ ថ្លៃទីផ្សារមូលដ្ឋាន របស់ជំនួស និងតម្លៃពេលវេលា ។ វិធីសាស្ត្រថ្លៃទីផ្សារមូលដ្ឋានផ្អែកលើថ្លៃនៅកសិដ្ឋាន ពោលគឺ ថ្លៃលក់ផលិតផល ។ វិធីសាស្ត្រជំនួស (substitue method) ប្រើព័ត៌មានបានមកពីទីផ្សារនៅក្បែរគ្នា ហើយវិធីសាស្ត្រតម្លៃពេលវេលា (time method) ផ្អែកលើការចំណាយពេលប្រមូលផល គុណនឹងថ្លៃឱកាសនៃកំលាំងពលកម្មក្នុងមូលដ្ឋាន ។

## លទ្ធផល

### *ថ្លៃផលព្រៃឈើ*

មានតែវិធីសាស្ត្រថ្លៃទីផ្សារមូលដ្ឋាន និងវិធីសាស្ត្រជំនួស ប៉ុណ្ណោះដែលអាចប្រើ ដើម្បីប៉ាន់ស្មានថ្លៃផលិតផលបានពីព្រៃឈើទាំងអស់បាន (កែច្នៃរួច និងមិនទាន់កែច្នៃ) ។ ទោះបីវិធីសាស្ត្រតម្លៃពេលវេលា គេតែងប្រើជាទូទៅសម្រាប់វាយតម្លៃការធ្វើកសិកម្មក្តី ប៉ុន្តែវាពិបាកអនុវត្តប្រើជាក់ស្តែង សម្រាប់វាយតម្លៃផលព្រៃឈើក្នុងតំបន់សិក្សារបស់យើង ។ វិធីសាស្ត្រទីផ្សារមូលដ្ឋាន មានប្រើជាញឹកញាប់សម្រាប់វាយតម្លៃ ដល់ទៅ ៧១% នៃផលព្រៃឈើសរុប ចំណែកឯ ២៩% ទៀត គេវាយតម្លៃតាមប្រើវិធីសាស្ត្រជំនួស (តារាង ១) ។ លទ្ធផលស្រាវជ្រាវបង្ហាញថា គ្រួសារគំរូតាងប្រមូលយកផលព្រៃឈើខុសៗគ្នាជាច្រើនយ៉ាង (កែច្នៃរួច និងមិនទាន់កែច្នៃ) ដែលបញ្ជាក់ពីតួនាទីដ៏សំខាន់នៃព្រៃឈើក្នុងការផ្គត់ផ្គង់ និងទ្រទ្រង់ជីវភាពនៅមូលដ្ឋាន ។ ផលព្រៃឈើខ្លះ ដូចជា សរសរ និងសត្វព្រៃ-ថនិកសត្វ បង្ហាញនូវគំលាត

ស្គង់ជាយ៉ាងធំ ដោយសារផលព្រៃឈើមុខខ្លះ ត្រូវបានបែងចែកជាអនុក្រុមជាច្រើន ផ្អែកលើគុណភាពខុសៗគ្នា ដូចជា ទំហំ ពូជ ឬផ្នែកនៃរុក្ខជាតិនោះ ។

ផលព្រៃឈើខ្លះ គេនិយមតែក្នុងតំបន់ជាក់លាក់ណាមួយ ហើយខ្លះទៀតគេស្គាល់ជាទូទៅនៅគ្រប់តំបន់ ។ ផលព្រៃឈើចំបងប្រាំមុខ ដែលគេរាយការណ៍ញឹកញាប់បំផុត គឺ អុស ទំពាំង ធ្យូង ឈើហ៊ុប និងឈើអារ ។ ជាទូទៅ ប្រជាជននៅក្នុងតំបន់សិក្សាទាំង៣ តែងធ្វើការប្រមូលអុស និងទំពាំង ។ ធ្យូង និងឫស្សីសម្រាប់ធ្វើបង្គោង (សម្រាប់ឡើងដើមត្នោត) ជាផលព្រៃឈើដែលគេតែងសង្កេតឃើញញឹកញាប់ នៅឃុំសង្កែសាទប ខេត្តកំពង់ស្ពឺ ហើយ ឈើហ៊ុប និងឈើអារ តែងឃើញញឹកញាប់នៅឃុំទំរីង ខេត្តកំពង់ធំ ។

តារាង១៖ តម្លៃផលព្រៃឈើប្រមូលបានដោយគ្រួសារគំរូតាង (គិតជារៀល)

| ផលព្រៃឈើ | ឯកតានៅមូលដ្ឋាន | បរិមាណ | អប្បរមា | អតិបរមា | មធ្យម | គំលាតស្តង់ដា | វិធីសាស្រ្ត |
|---|---|---|---|---|---|---|---|
| ផលព្រៃឈើ | | | | | | | |
| សរសរ | ដើម | 38 | 500 | 45000 | 5971 | 8709 | ទីផ្សារមូលដ្ឋាន |
| ឫស្សី | រទេះគោ | 11 | 3000 | 120000 | 43455 | 40636 | ទីផ្សារមូលដ្ឋាន |
| មែកឈើ | រទេះគោ | 10 | 5000 | 50000 | 24100 | 17489 | ទីផ្សារមូលដ្ឋាន |
| ឈើហ៊ុប | ដើម | 108 | 2000 | 300000 | 52847 | 64476 | ទីផ្សារមូលដ្ឋាន |
| បង្គោលរបង | ដើម | 91 | 250 | 15000 | 3095 | 2598 | ទីផ្សារមូលដ្ឋាន |
| ផ្សិត | គីឡូក្រាម | 69 | 500 | 10000 | 3797 | 2375 | ទីផ្សារមូលដ្ឋាន |
| មើមនិងឫសផ្សេងៗ | គីឡូក្រាម | 5 | 2000 | 10000 | 5200 | 3947 | ទីផ្សារមូលដ្ឋាន |
| សត្វព្រៃ-ថនិកសត្វ | ដុំ | 47 | 1000 | 150000 | 16362 | 32644 | ទីផ្សារមូលដ្ឋាន |
| សត្វព្រៃ-សត្វល្មូន | ដុំ | 41 | 1000 | 10000 | 4598 | 2584 | ទីផ្សារមូលដ្ឋាន |
| សត្វព្រៃ-សត្វល្អិត/ដង្កូវ | ចានគោម | 12 | 500 | 3000 | 1500 | 826 | ទីផ្សារមូលដ្ឋាន |
| សត្វព្រៃ-កង្កែប/គីង្គក់/ហ៊ីង | ដុំ | 13 | 50 | 500 | 242 | 161 | ទីផ្សារមូលដ្ឋាន |
| ដើមតាលព្រឹក្ស(អំបូរត្នោត) | ដើម | 38 | 100 | 250 | 201 | 39 | ទីផ្សារមូលដ្ឋាន |
| គមតាលព្រឹក្ស | គម | 36 | 100 | 500 | 265 | 128 | ទីផ្សារមូលដ្ឋាន |
| ទំពាំង | គីឡូក្រាម | 295 | 200 | 2500 | 864 | 577 | ទីផ្សារមូលដ្ឋាន |
| ក្តាម ខ្យង កំពឹស បង្កង | គីឡូក្រាម | 80 | 300 | 10000 | 2591 | 2148 | ទីផ្សារមូលដ្ឋាន |
| អុស | រទេះគោ | 668 | 3000 | 70000 | 23154 | 13533 | ជំនួស |
| វល្លិ | បាច់ | 5 | 1000 | 5000 | 2500 | 1732 | ជំនួស |
| ផ្តៅ | ដើម | 12 | 100 | 1000 | 213 | 255 | ជំនួស |
| ផ្លែឈើព្រៃ | ស្បោង/ការ៉ុង | 5 | 4000 | 25000 | 13800 | 9203 | ជំនួស |
| បន្លែព្រៃ | មួយដៃ | 55 | 200 | 3000 | 867 | 628 | ជំនួស |
| រុក្ខជាតិឱសថ | កំសៀវ | 19 | 1000 | 10000 | 3716 | 2776 | ជំនួស |
| ជ័រឈើ | គីឡូក្រាម | 11 | 300 | 1600 | 927 | 410 | ជំនួស |
| ស្បូវ | រទេះគោ | 9 | 5000 | 60000 | 27000 | 17457 | ជំនួស |
| សត្វព្រៃ-សត្វស្លាប/ប្រជៀវ | ដុំ | 33 | 1000 | 30000 | 4521 | 7286 | ជំនួស |
| ផលព្រៃឈើកែច្នៃរួច | | | | | | | |
| ឈើបន្ទះ | ម៉ែត្រគូប | 101 | 200000 | 3000000 | 748515 | 379294 | ទីផ្សារមូលដ្ឋាន |
| ធ្យូង | ឡូ | 262 | 6000 | 1200000 | 322389 | 169047 | ទីផ្សារមូលដ្ឋាន |
| គ្រឿងសង្ហារឹមធ្វើពីឈើ | ដុំ | 22 | 1500 | 400000 | 70295 | 85903 | ទីផ្សារមូលដ្ឋាន |
| គ្រឿងសង្ហារឹមធ្វើពីផ្តៅ | ដុំ | 10 | 2500 | 25000 | 8800 | 6642 | ទីផ្សារមូលដ្ឋាន |
| គ្រឿងសង្ហារឹមធ្វើពីឫស្សី | ដុំ | 7 | 300 | 15000 | 5686 | 5324 | ទីផ្សារមូលដ្ឋាន |
| គ្រឿងប្រក់ដំបូល | កណ្តប | 11 | 400 | 1000 | 664 | 196 | ទីផ្សារមូលដ្ឋាន |
| ទំពាំង | គីឡូក្រាម | 10 | 500 | 15000 | 6150 | 5623 | ទីផ្សារមូលដ្ឋាន |

ក្រាហ្វិក ២៖ ប្រាក់ចំណូលគ្រួសារសរុបតាមត្រីមាស




## ប្រាក់ចំណូលគ្រួសារជាមធ្យម

លទ្ធផលស្រាវជ្រាវបង្ហាញថា ប្រាក់ចំណូលប្រចាំឆ្នាំរបស់គ្រួសារក្នុងអង្កេត គឺ ២.០៤៩.០០០រៀល (៥០៦ដុល្លារ) ។ Bruce *et al.* (2004) ក៏រាយការណ៍ពីចំណូលគ្រួសារប្រចាំឆ្នាំជាមធ្យមស្រដៀងគ្នាដែរ គឺ ២.១៧៧.៨២៤រៀល (៥៣៨ដុល្លារ)[២] នៅខេត្តកំពង់ធំ និង ២.០១៩.៩៥២រៀល (៤៩៩ដុល្លារ) នៅខេត្តមណ្ឌលគិរី ។ ក្រុមស្រាវជ្រាវរកឃើញទៀតថា ប្រាក់ចំណូលគ្រួសារ ប្រែប្រួលពីត្រីមាសមួយទៅត្រីមាសមួយ និងទៅតាមរដូវ ។ គ្រួសារនានារកចំណូលបានប្រហែល ៦០០.០០០រៀល (១៤៨ដុល្លារ) ក្នុងពីរត្រីមាសដំបូង ដែលជារដូវប្រាំង (ក្រាហ្វិក ២) ។ ប៉ុន្តែប្រាក់ចំណូលថយចុះមកត្រឹម ៤៥៥.០០០រៀល (១១២ដុល្លារ) ក្នុងត្រីមាសទី៣ និង ៣៨៧.០០០រៀល (៩៦ដុល្លារ) ក្នុងត្រីមាសទី៤ ដែលស្ទើរតែស្ថិតក្នុងរដូវវស្សាទាំងស្រុង ។ ប្រាក់ចំណូលធ្លាក់ទាបក្នុងត្រីមាសទី៣ និងទី៤ ដោយសារកសិករចំណាយពេលភាគច្រើនធ្វើស្រែរបស់ខ្លួន ដូចជា រៀបចំដី ស្ទូង ថែទាំស្រូវ និងច្រូតកាត់ ជាដើម ។ ប៉ុន្តែសកម្មភាពរបស់ពួកគេក្នុងរយៈពេលនោះ វារួមចំណែកបង្កើនប្រាក់ចំណូលក្នុងត្រីមាសទី១ និងទី២ ។

## ចំណែកប្រាក់ចំណូលបានពីព្រៃឈើ ក្នុងចំណូលគ្រួសារជាមធ្យម

ប្រាក់ចំណូលសរុបទទួលបានពីប្រភពផ្សេងៗ អាចចែកជា ៤ក្រុមសំខាន់ៗ៖ ព្រៃឈើ កសិកម្ម (ដំណាំ និងសត្វចិញ្ចឹម) មជ្ឈដ្ឋានដទៃទៀត និងផ្នែកផ្សេងៗ (ភាគច្រើនជាប្រាក់ឈ្នួលកំលាំងពលកម្ម) (តារាង ២) ។ ប្រាក់ចំណូលបានពីកសិកម្ម (ស្រូវអង្ករ) ជាកត្តារួមចំណែកចំបងដល់ចំណូលសរុបនៅត្រីមាសទី១ គឺស្មើនឹង ៣០២.៤៦៨រៀល ឬ ៥១% នៃចំណូលសរុបប្រចាំត្រីមាស ។ យើងរកឃើញទៀតថា ប្រាក់ឈ្នួលពលកម្ម ជាប្រភពចំណូលចំបងសម្រាប់ត្រីមាសទី១ ទី២ និងទី៣ ។ ម្យ៉ាងទៀត ចំណូលបានពីផលព្រៃឈើ ជាប្រភពចំណូលចំបងទី៣ សម្រាប់គ្រប់ត្រីមាស ដែលបញ្ជាក់ជាថ្មីពីតម្លៃនៃព្រៃឈើក្នុងប្រាក់ចំណូលរកបាន ក៏ដូចជាការរួមចំណែកនៃព្រៃឈើក្នុងការកាត់បន្ថយភាពក្រីក្រ ។ ធនធានព្រៃឈើ មានចំណែកក្នុងចំណូលសរុបប្រចាំត្រីមាសរបស់អ្នកភូមិ ចាប់ពី ១៣% នៅត្រីមាសទី១ រហូតដល់ ៣១% នៅត្រីមាសទី៣ ។

ក្រុមស្រាវជ្រាវ ក៏បានវិភាគពីប្រាក់ចំណូលនៃគ្រួសារបែងចែកជា ក្រុមបញ្ចភាគ ដោយក្រុមបញ្ចភាគទី១ ជាក្រុម

តារាង ២៖ ចំណូលគ្រួសារប្រចាំត្រីមាសគិតតាមប្រភព (ជារៀល)

| ចំណូលពីមជ្ឈដ្ឋាននីមួយៗ | ត្រីមាសទី១ | | ត្រីមាសទី២ | | ត្រីមាសទី៣ | | ត្រីមាសទី៤ | |
|---|---|---|---|---|---|---|---|---|
| | មធ្យម | % | មធ្យម | % | មធ្យម | % | មធ្យម | % |
| ព្រៃឈើ | 74928 | 13 | 157948 | 26 | 139908 | 31 | 117791 | 30 |
| កសិកម្ម | 302468 | 51 | 185814 | 30 | 41777 | 9 | 77279 | 20 |
| មជ្ឈដ្ឋានផ្សេងទៀត | 21021 | 4 | 22961 | 4 | 44888 | 10 | 41671 | 11 |
| ផ្សេងៗ (ប្រាក់ឈ្នួល) | 198130 | 33 | 243034 | 40 | 228950 | 50 | 150774 | 39 |
| *សរុប* | *596547* | *100* | *609757* | *100* | *455523* | *100* | *387516* | *100* |

២ ១ដុល្លារ = ៤០៤៨រៀល (អត្រាប្តូរប្រាក់ជាមធ្យមក្នុងអំឡុងពេលសិក្សា ឆ្នាំ២០០៨) ។

ក្រាហ្វិក ៣៖ ចំណែកនៃចំណូលបានពីព្រៃឈើ ក្នុងចំណូលគ្រួសារសរុប គិតតាមក្រុមបញ្ចភាគប្រាក់ចំណូល




មានចំណូលទាបជាងគេ ។ ក្រាហ្វិក ៣ បង្ហាញថា ប្រាក់ចំណូលពីព្រៃឈើ រួមចំណែក ២៤% ក្នុងចំណូលសរុបនៃគ្រួសារមានចំណូលទាប ។ ចំណូលពីព្រៃឈើ រួមចំណែក ២៦% ក្នុងចំណូលសរុប នៃគ្រួសារមានចំណូលមធ្យម ដែលបង្ហាញថា គ្រួសារក្នុងក្រុមនេះ ពឹងផ្អែកលើចំណូលបានពីធនធានព្រៃឈើច្រើនជាងក្រុមមានប្រាក់ចំណូលទាប ។ រឿងនេះប្រហែលមកពីគ្រួសារមានចំណូលមធ្យម គេមានឧបករណ៍ និងមធ្យោបាយល្អជាង សម្រាប់ការប្រមូលផល និងការដឹកជញ្ជូនផលព្រៃឈើ ដូចជា ឧបករណ៍កាប់ឈើ រទេះគោ ឬក្របី ដែលជួយឲ្យពួកគេប្រមូលធនធានព្រៃឈើបានច្រើនជាង ។

ក្រុមទី៥ (ឬក្រុមមានចំណូលខ្ពស់បំផុត) និងក្រុមមានចំណូលទាបបំផុត ទទួលបានចំណូលពីផលព្រៃឈើ គិតជាភាគរយនៃប្រាក់ចំណូលសរុប ស្ទើរតែដូចគ្នា គឺ ប្រមាណ ២៤% ។ ចំណូលពីព្រៃឈើ មានចំណែកតូចនៅក្នុងប្រាក់ចំណូលសរុបរបស់គ្រួសារមានចំណូលទាបបំផុត ដោយសារជាសំខាន់ ពួកគេខ្វះឧបករណ៍ និងមធ្យោបាយដឹកជញ្ជូន ដែលធ្វើឲ្យពួកគេអាចប្រមូលផលព្រៃឈើបានតិច ។

ទោះបី ក្រុមចំណូលខ្ពស់បំផុត និងក្រុមចំណូលទាបបំផុត មានកម្រិតភាគរយប្រហាក់ប្រហែលគ្នា នៃចំណូលពីព្រៃឈើនៅក្នុងចំណូលសរុបក្តី ប៉ុន្តែបើគិតជាទឹកប្រាក់ បរិមាណផលពីព្រៃឈើរបស់ក្រុមចំណូលខ្ពស់បំផុត វាមានចំនួនច្រើនជាងបរិមាណផលពីព្រៃឈើ ដែលក្រុមចំណូលមធ្យម និងក្រុមចំណូលទាបបំផុតរកបាន ពីព្រោះក្រុមចំណូលខ្ពស់ គេមានប្រភពចំណូលច្រើន ព្រមទាំងមានមធ្យោបាយដឹកជញ្ជូន ឧបករណ៍ប្រមូលផល និងទ្រព្យសកម្មផ្សេងទៀតល្អជាង ដែលអាចឲ្យពួកគេទាញផលចំណេញបានច្រើនពីធនធានព្រៃឈើ ។

ការសិក្សារបស់ Hansen and Neth (2006) បង្ហាញថា គ្រួសារនានាទទួលបានអត្ថប្រយោជន៍ពីធនធានព្រៃឈើ កាន់តែតិចទៅៗ ។ Hansen and Neth (ibid) រាយការណ៍ថា គ្រួសារចំណូលមធ្យម ទទួលបានចំណូលពីផលនិងអនុផលព្រៃឈើប្រមាណ ៣០% នៃតម្លៃជីវភាពសរុបរបស់ពួកគេ ហើយគ្រួសារក្រីក្រទទួលបាន ៤២% ។ រឿងនេះបណ្តាលមកពីកត្តាជាច្រើន ដូចជា ការប្រែប្រួលប្រភពចំណូល ឬការថយចុះធនធានព្រៃឈើ ។

## សេចក្តីសន្និដ្ឋាន

តម្លៃនៃផលព្រៃឈើ អាចប៉ាន់ស្មានតាមរយៈវិធីសាស្ត្រថ្លៃលក់នៅកសិដ្ឋាន (ទីផ្សារមូលដ្ឋាន) និងវិធីសាស្ត្រជំនួស ។ វិធីសាស្ត្រថ្លៃលក់នៅកសិដ្ឋាន ផ្តល់តួលេខប៉ាន់ស្មានត្រឹមត្រូវជាងអំពីតម្លៃផលព្រៃឈើ រីឯវិធីសាស្ត្រជំនួស ផ្តល់តួលេខប៉ាន់ស្មានចោលៗជាង ។

ការវាយតម្លៃជាទឹកប្រាក់ នូវធនធានព្រៃឈើដែលអ្នកភូមិប្រើ (លក់ដូរ និងប្រើប្រាស់) វាចាំបាច់ណាស់ ដើម្បីយល់ដឹងកាន់តែប្រសើរ ពីអត្ថប្រយោជន៍នៃធនធានព្រៃឈើចំពោះជីវភាពនៅមូលដ្ឋាន ។ ប៉ុន្តែការវាយតម្លៃហ្មត់ចត់ទាមទារពេលវេលាច្រើន ដើម្បីចម្រាញ់យកព័ត៌មាន និងទិន្នន័យដែលប្រមូលបាន ដោយការប្រើវិធីសាស្ត្រជំនួស ។ ម្យ៉ាងទៀត ការវាយតម្លៃផលព្រៃឈើតាមថ្លៃទីផ្សារនៅមូលដ្ឋានដែលគេរាយការណ៍ឡើង ជួយឲ្យយើងមើលឃើញបានធំទូលាយពីតម្លៃផលព្រៃឈើ ដែលរួមចំណែកក្នុងចំណូលគ្រួសារ និងអាចឲ្យយើងប៉ាន់ស្មានបានពីការរួមចំណែកនៃធនធានព្រៃឈើក្នុងការកាត់បន្ថយភាពក្រីក្រ ។

ធនធានព្រៃឈើ ជាប្រភពចំណូលដ៏មានសំខាន់មួយ ។ ក្នុងការសិក្សានេះ ធនធានព្រៃឈើរួមចំណែក ២៦% ក្នុងចំណូលគ្រួសារសរុប សម្រាប់គ្រួសារក្នុងក្រុមចំណូលមធ្យម និង ២៤% សម្រាប់ក្រុមចំណូលទាប ។ គ្រួសារចំណូលខ្ពស់ ក៏

(តទៅទំព័រ ១៣)

# គណនេយ្យភាពនៅកម្ពុជា៖ ទ្រឹស្ដី និងការអនុវត្ត[១]

## សេចក្ដីផ្ដើម

សព្វថ្ងៃ គេឃើញពាក្យគណនេយ្យភាពលេចឡើងជាញឹកញាប់ នៅក្នុងឯកសារផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា និងម្ចាស់ជំនួយជាដៃគូអភិវឌ្ឍន៍នានា ។ ប៉ុន្តែយើងសង្កេតឃើញថា មានមនុស្សជាច្រើន ទាំងប្រជាជននិងមន្ត្រី ទាំងក្នុងនិងក្រៅជួររដ្ឋាភិបាល នៅស្រពិចស្រពិលអំពីអត្ថន័យពាក្យថ្មីនេះ ហើយការយកមកប្រើប្រាស់ ច្រើនផ្អែកតាមទ្រឹស្ដីរដ្ឋបាលសាធារណៈ និងអភិបាលកិច្ចនៅបស្ចិមប្រទេស ដោយមិនទាន់បានឆ្លុះបញ្ចាំងឱ្យដិតដល់អំពីបរិបទពិតប្រាកដនៅកម្ពុជាទេ ។

អត្ថបទនេះ មានបំណង (១) បំភ្លឺពីនិយមន័យពាក្យគណនេយ្យភាព (២) ធ្វើការបកស្រាយ និងចែករំលែកគំនិតទាក់ទងនឹងទ្រឹស្ដីសំខាន់ៗមួយចំនួន ដែលបានលើកឡើងស្ដីពីវិធីសាស្ត្រ សម្រាប់ធានាឱ្យមានគណនេយ្យភាពនៅក្នុងអភិបាលកិច្ចសាធារណៈ និង (៣)ផ្ដល់ជាគំនិតមួយចំនួនទាក់ទងនឹងការបន្តសិក្សាស្រាវជ្រាវអំពី គណនេយ្យភាពនៅក្នុងបរិបទកម្ពុជា ។

## អ្វីទៅជា "គណនេយ្យភាព"?

គណនេយ្យភាព ជាវាក្យស័ព្ទមួយយ៉ាងសំខាន់នៅក្នុងវិទ្យាសាស្ត្រនយោបាយ និងគណនេយ្យហិរញ្ញវត្ថុ ។ ប៉ុន្តែថ្មីៗនេះ គេបានយកវាទៅប្រើនៅក្នុងស្ថានភាពផ្សេងៗគ្នា ហើយឱ្យនិយមន័យផ្សេងៗគ្នា ដែលនាំឱ្យមានការភាន់ច្រឡំមួយចំនួន (Linberg 2009; Mulgan 2000) ។ នៅកម្ពុជា ចាប់តាំងពីមានការយកចិត្តទុកដាក់លើអភិបាលកិច្ចល្អ ពាក្យគណនេយ្យភាពនេះកាន់តែទទួលបាននូវប្រជាប្រិយភាព ។ ប៉ុន្តែជារឿយៗ អ្នកស្ដាប់ខ្លះ មានការស្រពិចស្រពិលពីអត្ថន័យពិត ឬក៏យល់ច្រឡំគណនេយ្យភាព ជាមួយនឹងកាងារចុះបញ្ជីគណនេយ្យ ។ ថ្មីៗនេះ មានមនុស្សកាន់តែច្រើនចាប់ផ្ដើមយល់ថា គណនេយ្យភាពមានន័យដូចគ្នានឹងការទទួលខុសត្រូវ ។ ដើម្បីជាការបំភ្លឺ អត្ថបទនេះផ្ដល់ការបកស្រាយដូចតទៅ៖

ដើម្បីជៀសវាងការភាន់ច្រឡំ គេគួរយល់ឲ្យច្បាស់លើទិដ្ឋភាពពីរផ្សេងគ្នា៖ (១) ធាតុសំខាន់ៗ និងប្រភេទនៃគណនេយ្យភាព និង (២) ប្រព័ន្ធអភិបាលកិច្ចដែលត្រូវមានជាចាំបាច់ ដើម្បីធានាបាននូវគណនេយ្យភាព (Linberg 2009) ។ ក្នុងទិដ្ឋភាពទី១ គណនេយ្យភាពត្រូវមានធាតុសំខាន់ចំនួន ៥ ដូចខាងក្រោម៖

(១) បុគ្គល ឬស្ថាប័នដែលត្រូវមានគណនេយ្យភាព
(២) មុខងារ តួនាទី និងដែននៃការទទួលខុសត្រូវ ដែលបុគ្គល ឬស្ថាប័ននោះ ត្រូវមានគណនេយ្យភាព
(៣) បុគ្គល ឬស្ថាប័នផ្សេងទៀត ដែលមានតួនាទីទាមទារគណនេយ្យភាព អំពីបុគ្គល ឬស្ថាប័នខាងលើ
(៤) សិទ្ធិរបស់បុគ្គល ឬស្ថាប័នទី២ ក្នុងការទាមទារឱ្យបុគ្គល ឬស្ថាប័នទី១ ត្រូវផ្ដល់ព័ត៌មាន និងពន្យល់ពីអ្វីដែលខ្លួនបានធ្វើ ទាក់ទងនឹងដែននៃការទទួលខុសត្រូវដែលបានប្រគល់ឱ្យ
(៥) សិទ្ធិរបស់បុគ្គល ឬស្ថាប័នទី២ ក្នុងការផ្ដល់រង្វាន់ ឬដាក់ទោសទណ្ឌដល់បុគ្គល ឬស្ថាប័នទី១ ផ្អែកតាមការបំពេញការងារ ក្នុងដែននៃការទទួលខុសត្រូវរបស់ខ្លួន ។

គណនេយ្យភាព អាចមានជាប្រភេទ នយោបាយ សង្គមកិច្ច ហិរញ្ញវត្ថុ ច្បាប់ ។ល។ គណនេយ្យភាពប្រភេទនីមួយៗ ត្រូវបានកំណត់ទៅតាមវិធាន និងស្ដង់ដារជាប់ពាក់ព័ន្ធ ។ ឧទាហរណ៍ គណនេយ្យភាពតាមផ្លូវច្បាប់ ត្រូវអនុលោមទៅតាមវិធានច្បាប់ដែលមាន រីឯគណនេយ្យភាពហិរញ្ញវត្ថុ ត្រូវផ្អែកទៅតាមវិធាននៃការគ្រប់គ្រងហិរញ្ញវត្ថុ ។ល។ វិធាន និងស្ដង់ដារទាំងនេះ ក្នុងករណីខ្លះ មិនចាំបាច់មានចែងជាលាយលក្ខណ៍អក្សរទេ ។ វិធាននិងទម្លាប់ខ្លះ ទោះមិនមែនជាច្បាប់ ក៏អាចមានឥទ្ធិពលខ្លាំងជាងច្បាប់ជាលាយលក្ខណ៍អក្សរទៅទៀត ។

តាមការសង្កេត ក្នុងការពិភាក្សាគោលនយោបាយនៅកម្ពុជា នៅពេលមានប្រើពាក្យគណនេយ្យភាព គេមិនសូវបានកំណត់ច្បាស់ទេ អំពីប្រភេទគណនេយ្យភាពដែលកំពុងផ្ដោតលើ គឺថា តើតួអង្គណា មានគណនេយ្យភាពចំពោះតួអង្គណា? ទៅលើដែននៃការទទួលខុសត្រូវណា? ត្រូវប្រើវិធាន ស្ដង់ដារ និងប្រព័ន្ធអភិបាលកិច្ចអ្វី ដើម្បីធានាឱ្យមានគណនេយ្យភាពដែលចង់បាន? រឿងនេះជាមូលហេតុមួយ ដែលនាំឱ្យមានការយល់ច្រឡំក្នុងចំណោមអ្នកចូលរួមក្នុងការពិភាក្សា ។

ប៉ុន្តែក្នុងករណីខ្លះ អ្នកពិភាក្សាមានការលំបាកនឹងបែងចែកឱ្យច្បាស់ ទៅតាមចំណុចនីមួយៗដូចខាងលើនេះ ដោយសារនៅក្នុងវិស័យសាធារណៈ គណនេយ្យភាពច្រើនប្រភេទអាចនៅលាយឡំគ្នា ហើយត្រូវមានវិធានច្រើនយ៉ាង ដើម្បីធានាឱ្យបានគណនេយ្យភាពទាំងនោះ ។ ម្យ៉ាងទៀត ក្នុងវិស័យសាធារណៈ មានតួអង្គច្រើននាក់ ហើយម្នាក់ៗអាចមានគណនេយ្យភាពក្នុងដែនការទទួលខុសត្រូវផ្សេងៗគ្នាក្នុងពេលតែមួយ និងត្រូវឆ្លើយតបចំពោះ បុគ្គល និងស្ថាប័នផ្សេងៗ លើសពីមួយ ។ ផ្នែកខាងក្រោម ជាការពិភាក្សាលើទ្រឹស្ដីសំខាន់ៗមួយចំនួន ដែលអាចជួយបំភ្លឺពីភាពស្មុគស្មាញទាំងនេះ ។

## ទ្រឹស្ដីសកលស្ដីពីការពង្រឹងគណនេយ្យភាព

គណនេយ្យភាព មានច្រើនប្រភេទក្នុងវិស័យសាធារណៈ ហើយសំខាន់ជាងគេ គឺ គណនេយ្យភាពនយោបាយ ដែលមន្ត្រីជាប់ឆ្នោត (ឬហៅថាមន្ត្រីនយោបាយ) ត្រូវមានចំពោះប្រជាជន

១ អត្ថបទនេះតាក់តែងឡើងដោយ លោក ប៉ក់ គឹមជឿន និងលោក គ្រុយ វីរៈ ជាអ្នកស្រាវជ្រាវនៅ CDRI ។

ជាម្ចាស់ឆ្នោត ។ ប៉ុន្តែមន្ត្រីនយោបាយពុំមានមធ្យោបាយឆ្លើយតបទៅនឹងរាល់តម្រូវការរបស់ប្រជាជននោះទេ ដូច្នេះ ត្រូវមានការបង្កើតជាក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ដែលជាអ្នកបច្ចេកទេសអនុវត្តការផ្ដល់សេវាដល់ប្រជាជន និងការងារផ្សេងទៀត ដែលរដ្ឋគួរធ្វើ ។ ក្នុងន័យនេះ មន្ត្រីបច្ចេកទេសត្រូវមានគណនេយ្យភាពចំពោះមន្ត្រីនយោបាយ ដែលគេហៅថា គណនេយ្យភាពរដ្ឋបាល ។

ទាំងក្នុងន័យនយោបាយ និងរដ្ឋបាល ធាតុទាំង ៥ នៃគណនេយ្យភាពនៅរក្សាដដែល ដូចជា៖ (១) អ្នកដែលត្រូវមានគណនេយ្យភាព (២) អ្នកដែលមានសិទ្ធិទាមទារឱ្យអ្នកទី១ ត្រូវមានគណនេយ្យភាព (៣) ការទទួលខុសត្រូវ ដែលអ្នកទី១ ត្រូវមានគណនេយ្យភាព (៤) ព័ត៌មានអំពីការអនុវត្តរបស់ជនដែលត្រូវមានគណនេយ្យភាព និង (៥) ការផ្តល់រង្វាន់ ឬការដាក់ទោសទណ្ឌទៅតាមអ្វីដែលអ្នកទី១ បានធ្វើ ។ ប៉ុន្តែរឿងថាតើប្រព័ន្ធអភិបាលកិច្ចមួយណាដែលគួរមកយកប្រើ ដើម្បីធានាឱ្យមានគណនេយ្យភាព វាជាចំណោទមួយដ៏ស្មុគស្មាញ ។ នៅខាងក្រោម គឺជាទ្រឹស្ដីសំខាន់ៗមួយចំនួន ដែលឆ្លើយនឹងសំណួរនេះ ។

ទ្រឹស្ដីទី១ ឈ្មោះថា ទ្រឹស្ដីគោលក្នុងរដ្ឋបាលសាធារណៈ ហៅកាត់ថា TPA និងរកឃើញដោយ សង្គមវិទូអាឡឺម៉ង់ឈ្មោះ Weber នៅដើមសតវត្សរ៍ទី២០ ។ ទ្រឹស្ដីនេះចែងថា ដើម្បីឱ្យរដ្ឋមួយ អាចបម្រើប្រជាជនបាន រដ្ឋនោះត្រូវមានប្រព័ន្ធរដ្ឋបាលមួយដែលអនុលោមតាមច្បាប់ និងដែលឡូស៊ិក ។ នៅក្នុងប្រព័ន្ធនោះ ការងារនយោបាយ និងបច្ចេកទេស ត្រូវបែងចែកឲ្យដាច់ពីគ្នា ហើយអ្នកតាក់តែងគោលនយោបាយ មិនត្រូវទទួលរងឥទ្ធិពលនយោបាយ ពីគណបក្សណាមួយឡើយ ។ នៅក្នុងប្រព័ន្ធរដ្ឋបាលសាធារណៈនេះ មានអនុប្រព័ន្ធជាច្រើនទៀត ដូចជា ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយទាំងអស់នេះត្រូវដើរតាមច្បាប់ និងវិធានជាសកលមួយ ។ មន្ត្រីនៅថ្នាក់ក្រោម ត្រូវមានគណនេយ្យភាពចំពោះមន្ត្រីដែលមានឋានានុក្រមខ្ពស់ជាង ដោយយោងតាមក្រឹត្យក្រមរដ្ឋបាលជាធរមាន ។ គណនេយ្យភាពក្នុងប្រព័ន្ធនេះផ្តោតជាសំខាន់ទៅលើអនុលោមភាពរបស់មន្ត្រីទាំងឡាយ ក្នុងការអនុវត្តការងាររបស់ខ្លួនទៅតាមច្បាប់ និងក្រឹត្យក្រម ជាធរមាន (Weber 1978) ។

ទ្រឹស្ដីខាងលើត្រូវបានគេទិតៀនថា មានលក្ខណៈរឹងកំព្រឹស និងមជ្ឈការខ្លាំង ។ ដើម្បីបំពេញលើចំណុចខ្វះខាតទាំងនេះ ទ្រឹស្ដីមួយទៀតឈ្មោះថា ការគ្រប់គ្រងវិស័យសាធារណៈបែបថ្មី ហៅកាត់ថា NPM ត្រូវបានតាក់តែងឡើងនៅទសវត្សរ៍ ១៩៥០ និង ១៩៦០ ដែលគាំទ្រឱ្យមានការគ្រប់គ្រងតាមបែបវិមជ្ឈការ និងផ្ដល់ឱ្យមន្ត្រីរាជការនូវឆន្ទានុសិទ្ធិ ភាពបត់បែន និងធនធានគ្រប់គ្រាន់ ក្នុងការអនុវត្តការងាររបស់ខ្លួន ។ ទ្រឹស្ដីនេះអះអាងថា ទាល់តែធ្វើបែបនេះទើបពួកគេអាចបំពេញតម្រូវការរបស់ប្រជាជនបាន ។ យោងតាម NPM គេបានជម្រុញសកម្មភាពកំណែទម្រង់សាធារណៈមួយចំនួន ដូចជា ការធ្វើឯកជនភាវូបនីយកម្ម ការជួលឱ្យភាគីក្រៅរដ្ឋាភិបាលបំពេញការងារដែលជាទំនួលខុសត្រូវរបស់រដ្ឋ ការគ្រប់គ្រងផ្អែកតាមលទ្ធផលការងារ ។ល។

តាមទ្រឹស្ដីនេះ គណនេយ្យភាពកើតមាន នៅពេលមន្ត្រីម្នាក់សម្រេចបានលទ្ធផលការងារដែលគេរំពឹងទុក ដោយមិនគ្រាន់តែសង្កត់ធ្ងន់ ទៅលើអនុលោមភាពតាមច្បាប់ជាធរមានប៉ុណ្ណោះទេ ។ ដូច្នេះ ការងារសំខាន់ គឺ ទី១ ត្រូវកំណត់ឱ្យបាននូវប្រព័ន្ធលើកទឹកចិត្តមួយសម្រាប់មន្ត្រី និងទី២ ត្រូវមានវិធានការគ្រប់គ្រាន់ ដើម្បីធានាថា មន្ត្រីទាំងនោះមិនរំលោភលើតួនាទីសិទ្ធិអំណាច និងធនធានដែលប្រគល់ឱ្យ (Minougue 2001) ។

នៅដើមទសវត្សរ៍១៩៨០ ទ្រឹស្ដីមួយទៀតឈ្មោះថា ប្រព័ន្ធស្ថាប័នថ្មី ហៅកាត់ថា NI បានលេចឡើង ។ ក្នុងទ្រឹស្ដីពាក្យស្ថាប័ននេះ មានអត្ថន័យធំទូលាយ និងអរូបី ដោយមិនគ្រាន់តែសំដៅលើអង្គភាព ឬអង្គការចាត់តាំងមួយនោះទេ ប៉ុន្តែមានន័យស្មើនឹង ក្បួន ច្បាប់ វិធាន ទម្លាប់នានា ដែលអាចចង និងកម្រិតសកម្មភាពរបស់មនុស្ស ។ ទ្រឹស្ដី NI នេះចែងថា ដើម្បីឱ្យវិស័យសាធារណៈ និងប្រព័ន្ធសេដ្ឋកិច្ចមួយ អាចបោះជំហានទៅមុខបាន គេត្រូវមានស្ថាប័ន (ពោលគឺ ក្បួន ច្បាប់ វិធាន ទម្លាប់) ដែលត្រឹមត្រូវ (North 1990) ។

ទ្រឹស្ដីនេះ ស្ដាប់ទៅហាក់មានវិសាលភាពយ៉ាងធំធេង ។ តាមខ្លឹមសារដូចខាងលើ ទ្រឹស្ដីនេះ ហាក់គ្មានអ្វីទាស់ខុសទេ ប៉ុន្តែមានគេទិតៀនថា វាទូលំទូលាយពេក រីឯនិយមន័យនៃពាក្យស្ថាប័ន ក៏ហាក់គ្មានអ្វីច្បាស់លាស់ ហើយក្នុងការប្រើប្រាស់ក៏មិនមានសង្គតិភាព ។ ទ្រឹស្ដីនេះ ហាក់មិនមានចែងច្បាស់អំពីគណនេយ្យភាពទេ ប៉ុន្តែគេសង្កេតឃើញថា ម្ចាស់ជំនួយជាច្រើននៅលោកខាងលិច បានផ្អែកលើវាក្នុងការផ្ដួចផ្ដើមគំនិតថ្មីៗទាក់ទងនឹងអភិបាលកិច្ចល្អ ដូចមានរៀបរាប់នៅខាងក្រោម៖

- ទី១ គឺ ទ្រឹស្ដីអំពីតួនាទីរបស់រដ្ឋ នៅក្នុងការអភិវឌ្ឍប្រទេសដែលហៅថា ទ្រឹស្ដីរដ្ឋមានសមត្ថភាព ដូចមានចែងក្នុងរបាយការណ៍អភិវឌ្ឍពិភពលោកឆ្នាំ១៩៩៧។នៅទសវត្សរ៍១៩៨០ និង ១៩៩០ អង្គការម្ចាស់ជំនួយជាច្រើន បានទិតៀនថា រដ្ឋ (សំដៅដល់រដ្ឋាភិបាល) គឺជាប្រភពបញ្ហានាំឱ្យការអភិវឌ្ឍដើរយឺត ដូច្នេះ តួនាទីនិងទំហំរបស់រដ្ឋ ត្រូវតែកាត់បន្ថយ ដើម្បីបើកផ្លូវឱ្យវិស័យឯកជន ចូលបំពេញតួនាទីជំនួសភាគច្រើន ដោយគេអះអាងថា វិស័យឯកជនអាចមានប្រសិទ្ធិភាពក្នុងការងារខ្ពស់ជាង ។ ក្រោយមក ទ្រឹស្ដីរដ្ឋមានសមត្ថភាព បានចាប់យកផ្លូវកណ្ដាល ដោយអះអាងថា រដ្ឋត្រូវមានតួនាទីក្នុងការអភិវឌ្ឍ តែមិនមែនទៅជំនួសវិស័យឯកជននោះទេ ប៉ុន្តែត្រូវជួយគាំទ្រដល់វិស័យឯកជនវិញ ។ បើនិយាយពីគណនេយ្យភាព ទ្រឹស្ដីនេះ ផ្ដោតលើរូបភាពរួមពោលគឺ គណនេយ្យភាពរវាងរដ្ឋ និងប្រជាជន ក្នុងប្រទេសមួយតែម្ដង ។ ទន្ទឹមគ្នានឹងការទទួលស្គាល់តួនាទីរបស់វិស័យឯកជន ទ្រឹស្ដីនេះលើកឡើងថា រដ្ឋមិនអាចគេចវេះពីគណនេយ្យភាព ក្នុងការផ្ដល់នូវសេវាកម្មបឋមដល់ប្រជាជនបានឡើយ (World Bank 1997) ។

ដើម្បីមានគណនេយ្យភាព រដ្ឋត្រូវបណ្តុះសមត្ថភាព ៣ យ៉ាងគឺ (១) សមត្ថភាពក្នុងការតាក់តែងគោលនយោបាយឲ្យសមស្របតាមតម្រូវការរបស់ប្រជាជន, (២) សមត្ថភាពក្នុងការអនុវត្តគោលនយោបាយទាំងនោះ ប្រកបដោយប្រសិទ្ធិភាព និង (៣) សមត្ថភាពក្នុងការជម្រុញឱ្យប្រជាជនចូលរួមក្នុងការទាមទារពីរដ្ឋ នូវគណនេយ្យភាពលើការងារក្នុងចំណុច(១) និង(២) ។

- គេបានយកទ្រឹស្តីនេះ មកបំបែក និងបំភ្លឺបន្ថែម នៅក្នុងរបាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ២០០៤ ដែលបង្កើតបានជាទ្រឹស្តីមួយទៀត ហៅថា គណនេយ្យភាពត្រីកោណ ។ មុំទាំង៣ នៃគណនេយ្យភាពនេះ គឺមានគណនេយ្យភាពរវាង (១) ប្រជាជន និងអ្នកផ្តល់សេវា (២) អ្នកផ្តល់សេវា និងអ្នកតាក់តែងគោលនយោបាយ និង (៣) អ្នកតាក់តែងគោលនយោបាយ និងប្រជាជន ។ មុំទី១ ជាផ្លូវកាត់ ផ្តោតចំតែលើការធ្វើយ៉ាងណា ឲ្យអ្នកផ្តល់សេវាមានគណនេយ្យភាពចំពោះប្រជាជន រីឯមុំទី២ និងទី៣ គួបគ្នាហៅថា ផ្លូវវាង ដោយហេតុថា ដើម្បីទទួលបានគណនេយ្យភាពលើការផ្តល់សេវា ប្រជាជនត្រូវធ្វើការទាមទារ តាមរយៈមន្ត្រីជាប់ឆ្នោត ដែលជាអ្នកតាក់តែងគោលនយោបាយ (World Bank 1997) ។

ដើម្បីឱ្យគណនេយ្យភាពត្រីកោណ អាចសម្រេចទៅបាន ត្រូវមានកត្តា ៥ យ៉ាង៖ (១) ការធ្វើប្រតិភូកម្ម (២) ការប្រគល់ធនធាន (៣) ការអនុវត្តការងារ (៤) ព័ត៌មានអំពីការអនុវត្តការងារ និង (៥) ការផ្តល់រង្វាន់ ឬការដាក់ទោសទណ្ឌ ទៅតាមលទ្ធផលការងារ ។ តាមទ្រឹស្តីនេះ ឧទាហរណ៍ ប្រសិនបើលោក សុខ ត្រូវមានគណនេយ្យភាពចំពោះការងារអ្វីមួយ ដំបូងគាត់ត្រូវទទួលបានការផ្ទេរមុខងារនិងការទទួលខុសត្រូវច្បាស់លាស់ និងការផ្ទេរធនធានសមរម្យទៅតាមមុខងារនោះ ។ រីឯ លោក សុខ ក៏ត្រូវមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីបំពេញការងារដែរ ។ ស្ថាប័ន ឬបុគ្គលដែលត្រូវទាមទារគណនេយ្យភាពពីលោក សុខ ត្រូវមានព័ត៌មានអំពីអ្វីដែលគាត់បានធ្វើ បើគាត់ធ្វើបានល្អ គួរមានការផ្តល់រង្វាន់ តែបើមិនបានល្អត្រូវដាក់ទោសទណ្ឌតាមស្ថានភាពជាក់ស្តែង។

- គណនេយ្យភាពត្រីកោណ ជាក្របខ័ណ្ឌមួយសម្រាប់ធ្វើការពិភាក្សាពីទ្រឹស្តីផ្សេងៗទៀត ទាក់ទងនឹងការលើកកម្ពស់គណនេយ្យភាពក្នុងវិស័យសាធារណៈ ។ ទ្រឹស្តីដ៏សំខាន់មួយគឺវិមជ្ឈការ ដែលថែងថា ការផ្ទេរសិទ្ធិនយោបាយ និងរដ្ឋបាល ច្រើនជាងមុន ឱ្យទៅថ្នាក់ក្រោមជាតិនិងមូលដ្ឋាន ធ្វើឱ្យរដ្ឋអាចឆ្លើយតបចំពោះតម្រូវការប្រជាជន បានកាន់តែល្អ គឺបានន័យថា រដ្ឋមានគណនេយ្យភាពល្អចំពោះប្រជាជន ។ សម្រាប់គណនេយ្យភាពត្រីកោណ ការធ្វើវិមជ្ឈការ អាចជួយបង្រួញផ្លូវវាង ព្រោះពេលនោះមន្ត្រីជាប់ឆ្នោតដែលជាអ្នកតាក់តែងគោលនយោបាយ បានខិតទៅជិតនឹងអ្នកទទួលសេវា ។

អ្នកគាំទ្រវិមជ្ឈការ បានអះអាងថា កំណែទម្រង់នេះនាំឱ្យមានកត្តាទាំង ៥ ដូចបានលើកឡើងខាងលើ ។ ឧទាហរណ៍ បន្ទាប់ពីបានបង្កើតក្រុមប្រឹក្សាថ្នាក់ក្រោមជាតិតាមទ្រឹស្តីវិមជ្ឈការ ត្រូវមាន ការផ្ទេរមុខងារ ការផ្ទេរសិទ្ធិក្នុងការប្រមូលពន្ធមូលដ្ឋាន មូលនិធិផ្ទេរពីរដ្ឋបាលថ្នាក់ជាតិផ្ទាល់ និងប្រព័ន្ធគ្រប់គ្រងមួយ ដែលអាចធានាបានថារដ្ឋបាលថ្នាក់ក្រោមជាតិ នឹងមានគណនេយ្យភាពចំពោះថ្នាក់ជាតិផង ចំពោះប្រជាជននៅមូលដ្ឋានផង និងរវាងតួអង្គសំខាន់នៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិខ្លួនឯងផង (Cheema and Rondinelli 2007) ។ ការងារនេះ គឺជាវិមជ្ឈការហិរញ្ញវត្ថុ ដែលកម្ពុជាបាននិងកំពុងអនុវត្ត ។

- ទ្រឹស្តីមួយទៀតហៅថា គណនេយ្យភាពសង្គម ជម្រុញឱ្យមានការធានាគណនេយ្យភាព តាមរយៈការផ្តល់សិទ្ធិអំណាចឲ្យប្រជាជន និងការចូលរួមរបស់សង្គមស៊ីវិល ។ តាមទ្រឹស្តីនេះ រដ្ឋទំនងជានឹងមានគណនេយ្យភាពច្រើនជាងមុន ប្រសិនបើ ប្រជាជន និងសង្គមស៊ីវិល មានសមត្ថភាព និងការត្រៀមខ្លួនដើម្បីធ្វើការទាមទារ ដូចជា តាមរយៈការបញ្ចេញមតិ ការតវ៉ា ការបង្កើតឱ្យមានការិយាល័យប្រជាពលរដ្ឋ ការចងក្រងជាក្រុម (World Bank 2005) ។

ទ្រឹស្តីនានាដូចបានរៀបរាប់ខាងលើ ភាគច្រើនចេញមកពីបស្ចឹមប្រទេស ជាពិសេសតាមរយៈទីភ្នាក់ងារផ្តល់ជំនួយរបស់គេ ។ ទ្រឹស្តីទាំងនេះ មួយផ្នែកកើតចេញពីបទពិសោធន៍ដែលទីភ្នាក់ងារទាំងនោះទទួលបាន តាមការផ្តល់ជំនួយទៅប្រទេសក្រីក្រ តាំងពីពេលចប់សង្គ្រាមត្រជាក់មក ។ តាមការបកស្រាយខាងលើ គេឃើញថា ទ្រឹស្តីទាំងនេះមានការផ្លាស់ប្តូរចុះឡើង ម្តងសង្កត់ធ្ងន់លើរដ្ឋ និងប្រព័ន្ធរដ្ឋបាលសាធារណៈ ម្តងងាកទៅផ្តោតលើវិស័យឯកជន និងក្រោយមក ព្យាយាមស្វែងរកតុល្យភាពរវាងតួអង្គទាំងពីរ ។

ក្នុង ២ទសវត្សរ៍ចុងក្រោយ ការពង្រឹងតួនាទីរបស់រដ្ឋហាក់ទទួលបានការយកចិត្តទុកដាក់ជាប់រហូត និងកាន់តែខ្លាំង ។ ទន្ទឹមគ្នានេះ ការឱ្យតម្លៃទៅលើអភិបាលកិច្ចល្អ ក៏កាន់តែសំខាន់ឡើងដែរ ។ ប៉ុន្តែក្នុងពេលកន្លងមក កំណែទម្រង់អភិបាលកិច្ចល្អ (ដូចជា កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ) នៅតាមប្រទេសក្រីក្រទូទាំងពិភពលោក ហាក់មិនទទួលបានលទ្ធផលគួរជាទីគាប់ចិត្តឡើយ ។ អ្នកជំនាញខ្លះចោទថា រឿងនេះមកពីការធ្វើកំណែទម្រង់មានមហិច្ឆតាធំពេក ចង់កែទម្រង់លើគ្រប់វិស័យ ។ គេផ្តល់យោបល់ថា ជាជាងសំដៅយកអភិបាលកិច្ចល្អឥតខ្ចោះ គេគួរសំដៅយកត្រឹមតែអភិបាលកិច្ចដែលល្អគ្រប់គ្រាន់មួយបានហើយ (Grindle 2004) ។

ថ្មីៗនេះ ម្យ៉ាងដោយសារកំណែទម្រង់រដ្ឋបាលសាធារណៈនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន មានភាពយឺតយ៉ាវ និងម្យ៉ាងទៀត ដោយសារឃើញមានចំណងទាក់ទងគ្នារវាងអភិបាលកិច្ច និងបញ្ហាសន្តិសុខ ទាំងនៅក្នុងប្រទេសនីមួយៗ និងជាអន្តរជាតិ ទ្រឹស្តីមួយទៀតហៅថា រដ្ឋផុយស្រួយ ក៏បានផុសឡើង (McLoughlin 2010) ។ គេបានឱ្យនិយមន័យរដ្ឋ

ផុយស្រួយ ថាជា រដ្ឋដែលមិនមានលទ្ធភាពឆ្លើយតបចំពោះតម្រូវការរបស់ប្រជាជន ទាំងលើការផ្ដល់សេវាសាធារណៈ សន្ដិសុខ និងនីតិរដ្ឋ ។ កង្វះខាតអភិបាលកិច្ចល្អ គឺជាមូលហេតុធ្វើឱ្យរដ្ឋផុយស្រួយ ។ ប៉ុន្ដែទ្រឹស្ដីនេះ ត្រូវគេទិតៀនថា ទូលំទូលាយពេកដោយចង់ដោះស្រាយទាំងបញ្ហាសន្ដិសុខផង និងអភិបាលកិច្ចផង ក្នុងពេលជាមួយគ្នា ។ គេរង់ចាំមើលថា តើទ្រឹស្ដីថ្មីនេះនឹងនាំមកនូវគំនិតថ្មីអ្វីខ្លះ សម្រាប់ជាប្រយោជន៍ដល់ការធ្វើកំណែទម្រង់ និងការពង្រឹងគណនេយ្យភាពក្នុងរដ្ឋបាលសាធារណៈ ។

## ចំណុចខ្លាំង ចំណុចខ្សោយនៃទ្រឹស្ដី និងការអនុវត្តនៅកម្ពុជា

រាល់ទ្រឹស្ដីសំខាន់ៗដូចខាងលើ សុទ្ធតែបានយកមកអនុវត្តនៅកម្ពុជា ។ ឧទាហរណ៍ កេរ្ដិ៍ដំណែលនៃប្រព័ន្ធរដ្ឋបាលសម័យអាណានិគមបារាំង នៅមានបន្ដមកដល់សព្វថ្ងៃ តួយ៉ាងដូចជា ការបែងចែកក្រសួង ស្ថាប័ន ប្រព័ន្ធគ្រប់គ្រងមន្ដ្រីរាជការ សហលក្ខន្ដិកៈមន្ដ្រីរាជការ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ល។ ទាំងអស់នេះ ជាឧទាហរណ៍ជាក់ស្ដែងនៃការយកមកអនុវត្តនូវទ្រឹស្ដី TPA នៅកម្ពុជា ។ ចំណែកឯ NPM វិញ មានយកមកអនុវត្តក្នុងរូបភាពនៃ ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ការចុះកិច្ចសន្យាឱ្យឯកជន ឬអង្គការមិនមែនរដ្ឋាភិបាល ធ្វើការផ្ដល់សេវាសុខាភិបាល និងការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ការប្រើថវិកាតាមកម្មវិធី ។ល។

ទ្រឹស្ដីផ្សេងទៀត ដូចជា រដ្ឋមានសមត្ថភាព វិមជ្ឈការ និងគណនេយ្យភាពសង្គម កំពុងមានអនុវត្តរាល់ថ្ងៃនៅកម្ពុជា ។ ឧទាហរណ៍ជាក់ស្ដែង មានដូចជា ការអនុវត្តកំណែទម្រង់ប្រព័ន្ធបោះឆ្នោត រដ្ឋបាលសាធារណៈ ហិរញ្ញវត្ថុសាធារណៈ វិមជ្ឈការ ការលើកកម្ពស់ការចូលរួមរបស់សង្គមស៊ីវិល ការបង្កើតឱ្យមានការិយាល័យប្រជាពលរដ្ឋនៅក្រុងបាត់ដំបង និងក្រុងសៀមរាប (Thon *et. al.* 2010) ។ ប៉ុន្ដែគេសង្កេតឃើញថា អ្នកស្ដាប់ភាគច្រើន មានការលំបាកយល់ និងការភ័ន្ដច្រឡំ នៅពេលព្យាយាម ផ្សារភ្ជាប់ទ្រឹស្ដី និងសកម្មភាពកំណែទម្រង់ទាំងនេះទៅនឹងពាក្យថា គណនេយ្យភាព ។

មានមូលហេតុពីរ ដែលបង្កការភ័ន្ដច្រឡំដូចខាងលើ ។ ទីមួយ គឺ ការមិនបានពន្យល់ឱ្យច្បាស់ ពីភាពខុសគ្នារវាងគណនេយ្យភាព ហើយនិងមធ្យោបាយដែលត្រូវមាន ដើម្បីធានាឱ្យបានគណនេយ្យភាព ។ សម្រាប់អ្នកស្ដាប់ភាគច្រើននៅកម្ពុជា គណនេយ្យភាព គឺជាលទ្ធផលដែលគេរំពឹងចង់បាន ។ ចំណែកឯនៅក្នុងទ្រឹស្ដីសកល គណនេយ្យភាព គឺជា លទ្ធផលផង និងជាដំណើរការ ឬមធ្យោបាយសម្រាប់ឱ្យមានលទ្ធផលនោះផង ។ ដើម្បីជៀសវាងការភ័ន្ដច្រឡំ គួរបញ្ជាក់បន្ថែមថា រាល់ទ្រឹស្ដី និងកំណែទម្រង់ដែលបានអនុវត្ត គឺជាដំណើរការ ឬមធ្យោបាយ ដើម្បីឱ្យមានគណនេយ្យភាព ។ ម្យ៉ាងទៀត មិនថាទ្រឹស្ដីណា ឬសកម្មភាពកំណែទម្រង់ណា ត្រូវបានដាក់អនុវត្តនោះទេ ខ្លឹមសារ និងធាតុរបស់គណនេយ្យភាព នៅរក្សាដដែល ដូចបានរៀបរាប់ក្នុងផ្នែកទី២ នៅខាងលើ ។

មូលហេតុទីពីរ ដែលនាំឱ្យមានការភ័ន្ដច្រឡំ គឺការមិនបានបញ្ជាក់ពីប្រភេទនៃគណនេយ្យភាព ដែលកំពុងពិភាក្សា ។ នៅក្នុងសង្គមប្រជាធិបតេយ្យ គណនេយ្យភាពដែលទូលំទូលាយជាងគេ គឺ គណនេយ្យភាពនយោបាយ រវាងមន្ដ្រីជាប់ឆ្នោត និងម្ចាស់ឆ្នោត ។ ប៉ុន្ដែគេក៏អាចយកគណនេយ្យភាពមកប្រើក្នុងន័យជាក់លាក់ និងតូចចង្អៀតជាងនេះបានដែរ ឧទាហរណ៍ ដូចជាគណនេយ្យភាព រវាងនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ រវាងមន្ដ្រីថ្នាក់ខ្ពស់ និងមន្ដ្រីក្រោមឱវាទ ឬក៏គណនេយ្យភាពរវាងសាលារៀន និងមាតាបិតាសិស្ស ។ល។

ចំណុចសំខាន់គួរពិចារណាមួយទៀត គឺ រាល់ទ្រឹស្ដីដូចបានរៀបរាប់ខាងលើ មានប្រភពចេញមកពីបស្ចិមប្រទេស ដូច្នេះ ពេលខ្លះមិនអាចឆ្លុះបញ្ចាំងបានគ្រប់ជ្រុងជ្រោយ អំពីគណនេយ្យភាពនៅកម្ពុជាទេ ។ រាល់សកម្មភាពកំណែទម្រង់ដែលបានអនុវត្តកន្លងមក ក៏សុទ្ធតែមានបង្កប់នូវការសន្មតថា ប្រទេសមួយ អាចមានគណនេយ្យភាពបាន លុះត្រាដើរតាមលម្អានរបស់លោកខាងលិច ។ ឈរលើការសន្មតនេះ កំណែទម្រង់ភាគច្រើនបានកំណត់ថា ការពង្រឹងគណនេយ្យភាព ជាការងារមួយអាចសម្រេចបាន ប្រសិនបើប្រព័ន្ធអភិបាលកិច្ចផ្លូវការរបស់រដ្ឋ បានរៀបចំឡើងទៅតាមលក្ខណៈបច្ចេកទេស ដែលដើរតាមគំរូរបស់លោកខាងលិច ។ ការកំណត់បែបនេះ មិនសូវប្រាកដនិយមទេ ព្រោះថា ការពង្រឹងគណនេយ្យភាពក្នុងវិស័យសាធារណៈ គឺជាការងារបច្ចេកទេសផង និងនយោបាយផង ដែលមិនផ្អែកទាំងស្រុង ទៅលើច្បាប់គ្រប់គ្រងរដ្ឋជាធរមាននោះទេ (ឧ. រដ្ឋធម្មនុញ្ញ) ប៉ុន្ដែទៅលើទំនាក់ទំនងរវាងបុគ្គល និងក្រុមអ្នកមានអំណាច ទៅលើទម្លាប់និងផ្នត់គំនិតរបស់មនុស្សក្នុងសង្គមទាំងមូលផងដែរ ហើយទាំងអស់នេះ សុទ្ធតែជាកត្តាកំណត់ថា អ្វីទៅគណនេយ្យភាព? គណនេយ្យភាពកើតមានពេលណា? ដោយសារអ្វី? ។ ដើម្បីយល់ដឹងពីកត្តាដែលមិនមានចែងក្នុងច្បាប់ទាំងនេះ ត្រូវមានទ្រឹស្ដីមួយផ្សេងទៀតជាជំនួយស្មារតី ។

## គណនេយ្យភាព និងទ្រឹស្ដីអំពីបរិវារកិច្ច

ការពិភាក្សានៅខាងលើ ផ្ដោតលើគណនេយ្យភាពអនុលោមតាមច្បាប់ និងវិធានជាផ្លូវការដាក់ចេញដោយរដ្ឋាភិបាល ។ ប៉ុន្ដែ គណនេយ្យភាពពុំមែនសុទ្ធតែកំណត់តាមអ្វីដែលមានចែងជាផ្លូវការនោះទេ ។ ពេលខ្លះ កត្តាដែលគ្មានចែងក្នុងច្បាប់ វាមានឥទ្ធិពលខ្លាំងជាងច្បាប់ទៅទៀត ដូចជា ទំនាក់ទំនងរវាងបុគ្គលតាមខ្សែ តាមខ្នង ជាដើម ។ ទំនាក់ទំនងបែបនេះ ហៅថា បរិវារកិច្ច (Scott 1977) ។

ការប្រាស្រ័យទាក់ទង តាមការស្គាល់គ្នា តាមខ្សែ-ខ្នង ជាទង្វើសាមញ្ញមួយក្នុងគ្រប់សង្គម ។ ការប្រាស្រ័យទាក់ទងបែបនេះ បង្កើតបានជាគណនេយ្យភាពមួយ រវាងអ្នកដែលជាខ្នង (មេ) និងអ្នកដែលដើរតាម (កូនចៅ) ដែលមានរូបភាពដូចតទៅៈ គណនេយ្យភាពនេះ គ្មានកំណត់តាមច្បាប់ ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សរអ្វីទេ ប៉ុន្ដែតាមការទុកចិត្ត និងការផ្ដល់ប្រយោជន៍ទៅវិញទៅមករវាងភាគីទាំងពីរ ។ ក្នុងន័យនេះ អ្នកតូច

ត្រូវមានគណនេយ្យភាពចំពោះអ្នកធំដែលជាខ្នងរបស់ខ្លួន ដោយត្រូវមានការស្មោះត្រង់ និងបម្រើ ឬផ្តល់ជាប្រយោជន៍អ្វីមួយដល់បុគ្គលនោះ ។ រីឯអ្នកធំវិញ ទោះគ្មាននិយាយ ឬចែងជាលាយលក្ខណ៍អក្សរអ្វី ក៏ត្រូវមានគណនេយ្យភាពចំពោះអ្នកតូចរបស់ខ្លួន ដោយត្រូវផ្តល់ការការពារ និងប្រយោជន៍មួយចំនួន ដែលភាគីទាំងសងខាងរំពឹងទុក ។ ដោយគ្មានអ្វីចែងជាលាយលក្ខណ៍អក្សរ ការរំពឹង និងទំនាក់ទំនង រវាងបុគ្គលនៅក្នុងបរិវារកិច្ចច្រើនអាស្រ័យទៅតាមទម្លាប់ពីមុនមក ឬតាមកត្តាវប្បធម៌ និងប្រពៃណីដែលមានស្រាប់ ។

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ បរិវារកិច្ចជ្រៀតចូលយ៉ាងជ្រៅ និងដំណើរការប្រកបដោយឥទ្ធិពលនៅក្នុងការងារគ្រប់គ្រងរដ្ឋបាលសាធារណៈ ។ ដូច្នេះ គណនេយ្យភាពតាមផ្លូវច្បាប់ (ដូចបានពិភាក្សាខាងលើ) តែងតែជំពាក់វាក់វិនជាមួយនឹងគណនេយ្យភាពតាមបែបបរិវារកិច្ច ។ បរិវារកិច្ចក្នុងន័យនេះអាចកើតមានរវាងមនុស្សតែពីរបីនាក់ ឬរវាងមនុស្សច្រើនរួមគ្នាជាប្រព័ន្ធមួយ ។ ក្នុងនោះ បុគ្គលម្នាក់អាចជាខ្នងរបស់មនុស្សរាប់សិបនាក់ដែលនៅក្រោមខ្លួន តែគាត់ក៏អាចជាអ្នកដើរតាម និងបម្រើសេវាដល់បុគ្គលម្នាក់ទៀតដែលមានឥទ្ធិពល និងជាខ្នងរបស់គាត់ដែរ ។ ទំនាក់ទំនងនេះប្រទាក់ក្រឡាគ្នាបង្កើតជាប្រព័ន្ធមើលមិនឃើញមួយ មានទម្រង់ដូចជាពីរ៉ាមីត ភ្ជាប់បន្តគ្នាតាំងពីអ្នកដែលមានអំណាចខ្លាំងបំផុត មកដល់អ្នកដែលតូចតាចនៅខាងក្រោម ។

នៅប្រទេសអាហ្វ្រិកមួយចំនួន បរិវារកិច្ចបានជ្រៀតចូលយ៉ាងខ្លាំងទៅក្នុងប្រព័ន្ធរដ្ឋបាលសាធារណៈ ដែលអនុញ្ញាតឱ្យមន្ត្រីគ្រប់ជាន់ថ្នាក់ អាចប្រើអំណាច និងខ្សែបណ្តាញ ដើម្បីប្រយោជន៍របស់ខ្លួន ដោយមិនគិតដល់ច្បាប់ និងផលប្រយោជន៍របស់សង្គមទេ ។ ប្រព័ន្ធបែបនេះ មិនមានបែងចែកច្បាស់រវាងអ្វីជាការងាររដ្ឋ និងអ្វីជាការងារ ឬប្រយោជន៍របស់បុគ្គលទេ ។ អ្នកស្រាវជ្រាវដែលសិក្សាពី ប្រព័ន្ធរដ្ឋបាលក្នុងប្រទេសអាហ្វ្រិកទាំងនេះ បានសន្និដ្ឋានថា បរិវារកិច្ច គឺជាមូលហេតុចំបងនាំឱ្យមានអំពើពុករលួយ និងកង្វះការអភិវឌ្ឍ (Bratton and van de Walle 1994) ។

អំពើពុករលួយជាបញ្ហាធំមួយ ដែលរាជរដ្ឋាភិបាលកំពុងព្យាយាមលុបបំបាត់ ហើយដែលទ្រឹស្តីបរិវារកិច្ចខាងលើ អាចជួយបំភ្លឺអំពីមូលហេតុ ។ ចំណុចសំខាន់ គឺ គួរពិនិត្យឲ្យហួសពីអ្វីដែលមានចែងនៅក្នុងច្បាប់ ហើយផ្តោតទៅលើខ្សែបណ្តាញរវាងបុគ្គលនៅក្នុងបរិវារកិច្ច និងវិធីដែលពួកគេប្រើអំណាច និងខ្សែបណ្តាញនោះ ដើម្បីទាញយក និងបែងចែកប្រយោជន៍នៅក្នុងក្រុមរបស់គេ ។ គួររំលឹកដែរថា ការអនុវត្តបែបនេះមិនមែនមានតែនៅកម្ពុជា ឬនៅប្រទេសអាហ្វ្រិកនោះទេ តែមាននៅគ្រប់សង្គម រួមទាំងប្រទេសរីកចម្រើនផង ។ ចំណុចខុសគ្នានៅត្រង់ថាប្រទេសកំពុងអភិវឌ្ឍន៍ មានបរិវារកិច្ចច្រើនរាលដាលស្ទើរគ្រប់វិស័យ តាំងពីលើដល់ក្រោម ហើយពេលខ្លះមានការប្រើឥទ្ធិពលបរិវារកិច្ចយ៉ាងចំហ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ។

តើទ្រឹស្តីនេះ អាចជួយបានកម្រិតណាក្នុងការស្វែងយល់ពីបញ្ហាគណនេយ្យភាពនៅកម្ពុជា? ជាចំណុចវិជ្ជមាន វាអាចជួយពន្យល់ពីលក្ខណៈជាប្រព័ន្ធ ឬជាបណ្តាញ នៃអំពើពុករលួយដែលកើតមានឡើង ។ ប៉ុន្តែប៉ុណ្ណេះ មិនទាន់គ្រប់គ្រាន់ឡើយ ពីព្រោះដើម្បីធ្វើកំណែទម្រង់ និងពង្រឹងគណនេយ្យភាព ត្រូវមានការយល់ដឹងលើសពីការចង្អុលថា បុគ្គលនេះ ឬក្រុមនោះជាជនពុករលួយ គ្មានគណនេយ្យភាពចំពោះច្បាប់ និងចំពោះប្រជាជន ។ ជាចំណុចអវិជ្ជមាន ទ្រឹស្តីនេះមើលឃើញរាល់រូបភាពនៃបរិវារកិច្ចថា សុទ្ធតែអវិជ្ជមាន និងរាំងស្ទះដល់ការអភិវឌ្ឍ (Picher *et. al.* 2009) ។ ការយល់ឃើញបែបនេះ ក៏ត្រឹមត្រូវដែរ ជាពិសេសបើពិនិត្យលើករណីរបស់ប្រទេសអាហ្វ្រិកក្រីក្រមួយចំនួនធំ ។ ប៉ុន្តែអ្នកសិក្សាលើការអភិវឌ្ឍនៅប្រទេសអាស៊ីមួយចំនួន ដូចជា កូរ៉េខាងត្បូង តៃវ៉ាន់ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងថៃ បានកត់សម្គាល់ថា ប្រទេសទាំងនេះ សុទ្ធតែធ្លាប់មានបរិវារកិច្ច និងអំពើពុករលួយយ៉ាងច្រើន ប៉ុន្តែ នៅតែអាចធ្វើការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនបាន (Khan and Jomo 2000) ។ ដូច្នេះ ទោះបី មានគណនេយ្យភាពបែបបរិវារកិច្ចយ៉ាងក្រាស់ក្រែលក៏ដោយ ក៏ក្នុងរយៈពេលវែង រដ្ឋាភិបាលក្នុងប្រទេសទាំងនេះនៅតែមានគណនេយ្យភាពចំពោះប្រជាជន ជាពិសេសលើការធានាឱ្យប្រជាជនមានជីវភាពល្អប្រសើរឡើង ។

ចំណុចសំខាន់មួយដែលបានរកឃើញ គឺមេដឹកនាំនៅក្នុងប្រទេសអាស៊ីជឿនលឿនដូចរៀបរាប់ខាងលើ ទោះមិនអាចបំបាត់អំពើពុករលួយបានទាំងស្រុង ក៏មានទេព្យកោសល្យល្អក្នុងការបង្វែរបរិវារកិច្ចទាំងនេះ ឱ្យមានប្រយោជន៍ខ្លះដល់ប្រព័ន្ធសេដ្ឋកិច្ចជាតិក្នុងរយៈពេលវែង ។ ឧទាហរណ៍ ទោះបីមានមន្ត្រីជាច្រើន បានប្រព្រឹត្តអំពើពុករលួយ និងមិនគោរពតាមគណនេយ្យភាពតាមផ្លូវច្បាប់ក្តី រដ្ឋាភិបាលនៅតែសម្រេចបានស្ថិរភាពនយោបាយ និងបរិយាកាសវិនិយោគល្អ ដែលជម្រុញឱ្យមន្ត្រីទាំងនោះ អាចប្រើធនធានរបស់ខ្លួនមកធ្វើវិនិយោគជាប្រយោជន៍ដល់សេដ្ឋកិច្ចក្នុងស្រុក ។ ករណីនេះ ខុសពីប្រទេសអាហ្វ្រិកមួយចំនួនធំ ដែលមន្ត្រីភាគច្រើនយកធនធានដែលខ្លួនរកបាន ទៅទុកក្នុងធនាគារនៅបស្ចិមប្រទេស ជាជាងធ្វើវិនិយោគក្នុងសេដ្ឋកិច្ចប្រទេសខ្លួន (Khan and Jomo 2000) ។

ភាពខុសគ្នារវាងករណីប្រទេសអាស៊ី និងអាហ្វ្រិក ជាឧទាហរណ៍បញ្ជាក់ច្បាស់ថា មិនមែនរាល់បរិវារកិច្ចសុទ្ធតែរាំងខ្ទប់ដល់ការអភិវឌ្ឍប្រទេសនោះទេ តែវាអាស្រ័យទៅតាមប្រភេទ និងស្ថានភាពនយោបាយ និងសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ ។ មួយវិញទៀត គេក៏មិនអាចរំពឹងឱ្យអភិបាលកិច្ច និងគណនេយ្យភាពក្នុងរដ្ឋមួយ ផ្លាស់ប្តូរពីទន់ខ្សោយ ទៅជារឹងមាំភ្លាមៗនោះដែរ គឺអ្វីៗត្រូវប្រព្រឹត្តទៅដោយសន្សឹមៗ ។ ដូច្នេះ អ្នកស្រាវជ្រាវត្រូវវិភាគលើលក្ខណៈនៃការវិវត្តសន្សឹមៗនេះ មុននឹងធ្វើការសន្និដ្ឋានអំពីលម្អាននៃការពង្រឹងគណនេយ្យភាពនៅក្នុងរដ្ឋមួយ (van de Walle 2007) ។

ការស្វែងយល់ពី គណនេយ្យភាពរដ្ឋបាលសាធារណៈនៅកម្ពុជា កាន់តែត្រូវមានការប្រយ័ត្នប្រយែងថែមទៀត ដោយសារប្រទេសនេះធ្លាប់ឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃ និងរបបប្រល័យពូជសាសន៍ដែលបានប៉ះពាល់យ៉ាងខ្លាំង មិនត្រឹមតែលើសមត្ថភាពរបស់រដ្ឋប៉ុណ្ណោះទេ ប៉ុន្តែទៅលើផ្នត់គំនិត និងទំនាក់ទំនង របស់

ប្រជាជនជាមួយរដ្ឋថែមទៀត ។ ឧទាហរណ៍ នៅពេលប្រជាជននៅប្រទេសជឿនលឿន សំដែងភាពក្លាហានទាមទារឱ្យរដ្ឋត្រូវតែមានគណនេយ្យភាពចំពោះខ្លួន ប្រជាជនកម្ពុជាបែរជាមានការខ្លាចរអារ ចង់តែជៀសឱ្យឆ្ងាយពីពាក្យថា រដ្ឋអំណាច ដោយហេតុថា ពួកគាត់ធ្លាប់ឆ្លងកាត់ព្រឹត្តិការណ៍ដ៏រន្ធត់ ដែលរដ្ឋធ្លាប់បានប្រព្រឹត្តមកលើខ្សែជីវិតរបស់គាត់ និងក្រុមគ្រួសារគាត់ ដូចជាក្នុងរបបខ្មែរក្រហម ជាដើម (Chandler 2008) ។

ចំណុចខាងលើបង្ហាញកាន់តែច្បាស់ថា ដើម្បីស្វែងយល់ពីគណនេយ្យភាពនៅកម្ពុជា គេមិនអាចបំភ្លេចចោលនូវកត្តាប្រវត្តិសាស្ត្រ និងសង្គមរបស់ប្រទេសនេះ ហើយទាញយកទ្រឹស្ដីតាមលោកខាងលិចមកប្រើដោយត្រង់ៗបានឡើយ ។ ចំណែកឯទ្រឹស្ដីបរិវារកិច្ចដូចបានរៀបរាប់ខាងលើ ក៏នៅមិនគ្រប់គ្រាន់ដែរ ម្យ៉ាងដោយសារទ្រឹស្ដីនេះ មានទំនោរអគតិខ្លាំងពេក និងម្យ៉ាងទៀត ដោយសារវាមិនឱ្យតម្លៃគ្រប់គ្រាន់ដល់អ្វីដែលហៅថា បរិបទជាក់ស្ដែងរបស់ប្រទេសនីមួយៗ ។ ការសិក្សាស្រាវជ្រាវគួរបន្តស្វែងយល់ថែមទៀត អំពីសារជាតិនៃពាក្យថា គណនេយ្យភាពនៅកម្ពុជា និងអំពីលម្អាននៃការវិវត្តរបស់វា ដោយសង្ឃឹមថា អាចហុចលទ្ធផលជាការបង្កើតបានទ្រឹស្ដីសំយោគមួយ ដែលស៊ីជាមួយនឹងបរិបទនៅកម្ពុជា ។

## សេចក្ដីសង្ខេប និងគំនិតសម្រាប់ការសិក្សាស្រាវជ្រាវនាពេលអនាគត

អត្ថបទនេះបង្ហាញថា នៅពេលពិភាក្សាអំពីគណនេយ្យភាព មានផុសសំណួរមួយចំនួនដែលត្រូវបកស្រាយ ។ ទីមួយ តើគណនេយ្យភាពប្រភេទអ្វីដែលគេកំពុងពិភាក្សា? សំណួរនេះសំដៅដល់គណនេយ្យភាពនយោបាយ រដ្ឋបាល ហិរញ្ញវត្ថុ ច្បាប់ ។ល។ ក្នុងនោះ តើអ្នកណាត្រូវមានគណនេយ្យភាពចំពោះអ្នកណា? លើដែនសមត្ថកិច្ចអ្វី? និងយោងតាមច្បាប់ និងវិធានអ្វី? ទីពីរ ត្រូវស្វែងយល់ឱ្យច្បាស់អំពីប្រព័ន្ធដែលយកមកប្រើ ដើម្បីធានាឱ្យមានគណនេយ្យភាពប្រភេទណាមួយនោះ ។ ត្រង់នេះ គេអាចយកមកប្រើនូវទ្រឹស្ដីមួយចំនួនដូចបានរៀបរាប់ខាងលើ ដើម្បីជួយដល់ការវិភាគ ។ ចំណុចមួយដែលគួរចងចាំគឺ គណនេយ្យភាពពុំមែនកំណត់តែតាមអ្វីដែលមានចែងជាច្បាប់ និងជាលាយលក្ខណ៍អក្សរនោះទេ ។ កត្តាផ្សេងទៀត ដូចជាបរិវារកិច្ច ជាដើម ក៏ជះឥទ្ធិពលខ្លាំងទៅលើគណនេយ្យភាពដែរ ។ ដូច្នេះ គេត្រូវមើលទាំងលើកត្តាផ្លូវការ និងកត្តាមិនផ្លូវការ និងទំនាក់ទំនងរបស់វាទាំងពីរ ។

ទាក់ទងនឹងការសិក្សាស្រាវជ្រាវបន្តអំពីគណនេយ្យភាព អត្ថបទនេះបង្ហាញថា នាបច្ចុប្បន្ន ការវិភាគភាគច្រើនពឹងផ្អែកលើទ្រឹស្ដីប្រទេសលោកខាងលិច ប៉ុន្តែខ្វះការឆ្លុះបញ្ចាំងមកក្នុងបរិបទជាក់ស្ដែងនៅកម្ពុជា ។ ភាគច្រើននៅពេលនិយាយពីបរិវារកិច្ចនៅកម្ពុជា គេច្រើនចាត់វាថា ជាទង្វើដែលនាំឱ្យមានអំពើពុករលួយ ។ ដូចបានលើកឡើងខាងលើ បរិវារកិច្ចពុំមែនសុទ្ធតែជាអំពើខុសឆ្គងទាំងអស់នោះទេ ។ វាអាចល្អ និងអាចមិនល្អ ។ ការសិក្សាថ្មីៗមួយចំនួនបង្ហាញថា ពេលខ្លះបរិវារកិច្ច ក៏អាចជួយដល់សង្គមដែរ ។ ដូច្នេះ សម្រាប់ប្រទេសកម្ពុជា៖

- ទីមួយ ក្នុងការសិក្សាស្រាវជ្រាវនាពេលអនាគត គួរស្វែងយល់បន្ថែមអំពីគណនេយ្យភាពតាមបរិវារកិច្ច និងផលវិជ្ជមាន និងអវិជ្ជមាន របស់វា ។ គួរមើលដែរថា តើគណនេយ្យភាពមានរូបភាពយ៉ាងណា នៅពេលដែលកំណែទម្រង់រដ្ឋ អនុវត្តលាយឡំគ្នាជាមួយបរិវារកិច្ច នៅក្នុងបរិបទជាក់លាក់ណាមួយ ដូចជានៅក្នុងការងារវិមជ្ឈការ ការផ្ដល់សេវាសាធារណៈ ការចូលរួមរបស់ប្រជាជនក្នុងសកម្មភាពសហគមន៍ ។ល។
- ទីពីរ ការសិក្សាអំពីគណនេយ្យភាពនៅកម្ពុជា គួរបន្តដកបទពិសោធន៍ពី ប្រទេសទើបងើបពីសង្គ្រាមផ្សេងទៀត ប៉ុន្តែក្នុងពេលជាមួយគ្នា គួរធ្វើការប្រៀបធៀប និងដកបទពិសោធន៍ឱ្យបានច្រើនថែមទៀត ពីប្រទេសនៅអាស៊ីអាគ្នេយ៍ ជាអាទិ៍ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ថៃ ឬ វៀតណាម ដែលជាប្រទេសមានវប្បធម៌ ប្រពៃណី និងកត្តាសង្គមមួយចំនួនស្រដៀងគ្នានឹងកម្ពុជា ។ នៅប្រទេសអាស៊ីអាគ្នេយ៍ទាំងនេះ គេបានកត់សំគាល់ថា មានការអនុវត្តបរិវារកិច្ច ការប្រើខ្សែខ្នងយ៉ាងក្រាស់ក្រែល ប៉ុន្តែនៅតែអាចធ្វើការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនបានយ៉ាងប្រសើរ (Khan and Jomo 2000) ។

ពិតណាស់ បណ្ដាប្រទេសដូចរៀបរាប់ខាងលើ គេមានវាសនាល្អជាងកម្ពុជា ព្រោះគ្មានសង្គ្រាមរ៉ាំរ៉ៃ គ្មានរបបប្រល័យពូជសាសន៍ និងមានការអភិវឌ្ឍក្នុងកម្រិតមួយ ដែលដាច់ឆ្ងាយពីកម្ពុជា ។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី សម្រាប់ការសិក្សាស្រាវជ្រាវ គេនៅតែអាចទទួលបានមេរៀនជាច្រើនទាក់ទងនឹងគណនេយ្យភាព ការធ្វើកំណែទម្រង់ និងបរិវារកិច្ច ជាពិសេសប្រសិនបើផ្ដោតការយកចិត្តទុកដាក់ ទៅលើអំឡុងពេលដែលប្រទេសទាំងនេះ ទើបមានស្ថិរភាពនយោបាយ និងសន្ទុះសេដ្ឋកិច្ចក្នុងពេល ២ ឬ ៣ទសវត្សរ៍ កន្លងទៅនេះ ។

## ឯកសារយោង


Bratton, M. & N. van de Walle (1994), "Neo-patrimonial regimes and political transition in Africa", *World Politics* 46 (4), pp. 453–489

Chandler, D. (2008). A history of Cambodia. Westview Press, Colorado

Cheema, G.S. & D.A. Rondinelli (eds.) (2007), *Decentralizing governance: Emerging concepts and practices* (Harrisonburg, VA: R.R. Donnelley)

Grindle, M. (2004), "Good enough governance: poverty reduction and reform in developing countries", Governance 17 (4), pp. 525–548

Khan, M. & K. Jomo (2000), Rent, rent seeking and economic development: theory and evidence in Asia (Cambridge: Cambridge University Press)

Lindberg, S.I. (2009), *Accountability: the core concept and its subtypes* (London: ODI)

McLoughlin, C. (2010), *Topic guide on fragile states,* (Birmingham: International Development Department)

Minogue, M. (2001), "The internationalization of new public management", in W. McCourt & M. Minogue (eds.), *The internationalization of public management* (Cheltenham, UK: Edward Elgar) pp. 1–19

Mulgan, R.D. (2000), "Accountability: An ever-expanding concept?", *Public Administration,* 78 (3), pp. 555–573

North, D.C. (1990), *Institutional change and economic performance* (Cambridge: Cambridge University Press)

Pak, K., V. Horng, N. Eng, S. Ann, S. Kim, J. Knowles and D. Craig (2007), *Accountability and noe-patrimonialism in cambodia: A critical literature review.* CDRI, Phnom Penh, Cambodia

Pitcher, A., Moran, M. and Johnston, M (2009), Rethinking Patrimonialism and Neopatrimonialism in Africa, *African Studies Review,* 52(1), 125-156

Scott, C. (1977), "Patron-client politics and political change." *Southeast Asia* (66): 91-113.

Thon, V, S. Heng, Kruy, V and Tem, L (2011). *Assessment of One Window Service Offices and District Ombudsmen Pilot Projects.* CDRI, Phnom Penh, Cambodia

van de Walle, N (2007), The path from neo-patrimonialism: democracy and clientelism in Africa today. *Center for International Studies* 3(07)

Weber, M (1978), *Economy and society.* Berkeley: University of California Press.

World Bank (1997), *The state in a changing world.* World Development Report 1997, Oxford University Press. Washington DC

World Bank (2004), *Making services work for poor people.* World Development Report, The World Bank, Washington DC

World Bank (2005), *Social accountability in the public sector: A conceptual and learning module,* The World Bank, Washington DC

---

*តពីទំព័រ ៦* **ព្រៃឈើ និង...**

ទទួលចំណូលពីព្រៃឈើបានប្រមាណ ២៤% នៃប្រាក់ចំណូលសរុបដែរ ប៉ុន្តែបើគិតជាសាច់ប្រាក់ គ្រួសារក្នុងក្រុមនេះ ទទួលអត្ថប្រយោជន៍ពីព្រៃឈើ បានច្រើនជាងក្រុមឯទៀតៗ ។

### ឯកសារយោង

Bruce, M. K., Yim, C., Prom, T., & Tom, E. (2004), Focusing on Cambodia's High Value Forests: Livelihood and Management (Phnom Penh: CDRI & Wildlife Conservation Society)

CFI (2006), Proceedings of non-timber forest products (NTFP) workshop and seminar held on 7-8 December 2006 in Phnom Penh

Chao L. (2009), Agricultural Mechanisation and Agricultural Development Strategies in Cambodia, country report for the fifth session of the technical committee of UNAPCAM held on 14-15 October 2009 in Los Banos, the Philippines

Chhatre, A. & Arun, A. (undated), Carbon Storage and Livelihoods Generation through Improved Governance of Forest Commons, IFRI Working Paper No. W09I.01 http://sitemaker.umich.edu/ifri/files/carbon_and_livelihoods_ver7.pdf (accessed 14 January 2011)

FAO (2010), Forest and Climate Change Working Paper No.7: Forest and Climate Change in the Asia-Pacific Region (Rome: FAO)

Hansen K. & Neth T. (2006), Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia,, CDRI Working paper No. 33 (Phnom Penh: CDRI)

Poverty and Environment Network (2007), Prototype Questionnaire Version 4 in English, , http://www.cifor.cgiar.org/pen (accessed 1 July 2008)

Poverty and Environment Network (2009) PEN Narrative (unpublished)

RGC (2010), National Strategic Development Plan, Update 2009-2013

Tola, Prom (2009), Beyond Subsistence: Trade Chain Analysis of Resin Products in Cambodia (Phnom Penh: NTFP Exchange Programme for South and Southeast Asia)